## សេចក្តីប្រកាសរបស់អ្នកនិពន្ធ

*ប្រាទូ* ជាទស្សនាវដ្តីស្តីពី សិល្បៈ ស្ថាបត្យកម្ម បុរាណវិទ្យាទាំងផ្នែកពុទ្ធសាសនា និងហិណ្ឌូសាសនា នៅសម័យបុរាណរហូតដល់មុនសម័យទំនើបនៅតំបន់អាស៊ីអាគ្នេយ៍ ដែលបង្កើតឡើងក្នុងគោលបំណងដើម្បីសម្រួលដល់អ្នកសិក្សាស្រាវជ្រាវថ្មីៗ ដែលទើបតែមានបទពិសោធន៍ក្នុងការបោះពុម្ព ផ្សាយលក្ខណៈវិទ្យាសាស្ត្រ ដោយសារគេទើបតែបញ្ចប់ភាពជានិសិត្សមកជាអ្នកមានវិជ្ជាជីវៈជាអ្នកសិក្សាស្រាវជ្រាវ។ *ប្រាទូ* សូមស្វាគមន៍រាល់ការចូលរួមចំណែកពីសំណាក់អ្នកសិក្សាស្រាវជ្រាវទាំងអស់ ហើយនឹងផ្តល់បរិយាកាសគាំទ្រជូនដល់អ្នកសិក្សាស្រាវជ្រាវទ ដើម្បីជួយឲ្យអ្នកទាំងអស់នោះ មានការយល់ដឹងអំពីដំណើរការ និងតម្រូវការសម្រាប់ការបោះពុម្ពផ្សាយបែបវិទ្យាសាស្ត្រលក្ខណៈអន្តរជាតិ។ ក្រុមអ្នកត្រួតពិនិត្យអត្ថបទនឹងធ្វើការជាមួយអ្នកនិពន្ធអត្ថបទ ដើម្បីពង្រឹងគុណភាពនៃអត្ថបទរបស់ពួកគេ និង សម្រួលក្នុងទទួលឲ្យបោះផ្សាយនៅក្នុង ទស្សនាវដ្តី *ប្រាទូ* ដោយឆ្លងកាត់ដំណើរការ នៃការផ្តល់មតិកែលម្អ ការវាយតម្លៃពីសំណាក់អ្នកដែលមានបទពិសោធន៍ក្នុងវិស័យនីមួយៗ និង ការកែសម្រួលខ្លឹមសារនៃអត្ថបទ។ អត្ថបទដែលសរសេរជាភាសានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ នឹងត្រូវបកប្រែជាភាសាអង់គ្លេសទាំងអស់។ អ្វីៗទាំងអស់នេះគឺធ្វើឡើងដើម្បីបង្កើននូវឱកាសជាសកលដល់អ្នកអាន អ្នកសិក្សាស្រាវជ្រាវ និងដើម្បីអភិវឌ្ឍនូវការសហការជាលក្ខណៈអន្តរជាតិ។

*ប្រាទូ* ស្នើថាអ្នកនិពន្ធត្រូវយល់ពីសារៈសំខាន់នៃកិច្ចការដែលនឹងត្រូវមានសម្រាប់ការរៀបចំអត្ថបទមួយ ដើម្បីបោះពុម្ពផ្សាយ។ ការពិនិត្យ និងកែសម្រួលអត្ថបទច្រើនលើក ច្រើនសារអាចនឹងត្រូវកើតមាន តាមភាពចាំបាច់ ហើយអាចនឹងមានការចូលរួមពីអ្នកខាងក្រៅផ្នែកសេវាបច្ចេកទេសផងដែរ។ ហេតុដូច្នេះ យើងសូមស្នើដល់អ្នកនិពន្ធទាំងអស់ត្រូវអនុវត្តតាមសេចក្តីណែនាំសម្រាប់ការប្រគល់អត្ថបទ (https://pratujournal.org/submit/) និង កាលបរិច្ឆេទប្រគល់អត្ថបទ និងការយល់ដឹងអំពី សិទ្ធិរបស់ *ប្រាទូ* ក្នុងការធ្វើការបោះពុម្ពផ្សាយលើកទីមួយ (https://pratujournal.org/about/)។ ក្រុមអ្នកត្រួតពិនិត្យរបស់ *ប្រាទូ* នឹងជួយណែនាំអ្នកនិពន្ធទាំងអស់ ក្នុងដំណើរការបោះពុម្ពផ្សាយនេះ ដើម្បីជួយពង្រឹងការយល់ដឹងអំពីកម្រិតនៃការបោះពុម្ពផ្សាយបែបវិទ្យាសាស្ត្រ។

*ប្រាទូ* រំពឹងទុកថា អ្នកនិពន្ធទាំងអស់នឹងធ្វើការសិក្សាស្រាវជ្រាវដោយគោរពតាមគោលការណ៍ដែលបានចែងដោយអង្គការ យូណេស្កូ ស្តីអំពី សន្ធិសញ្ញាអំពីការហាមឃាត់ និង ទប់ស្កាត់ ការនាំចូល នាំចេញ និងការផ្ទេរកម្មសិទ្ធិ នៃសម្បត្តិបេតិកភណ្ឌវប្បធម៌ដោយខុសច្បាប់ (១៩៧០) និង សន្ធិសញ្ញាបេតិកភណ្ឌពិភពលោក (១៩៧២) (អត្ថបទជាភាសាអង់គ្លេស)។ ទាំងនេះគឺគាំទ្រដល់ការការពារ អភិរក្ស ស្ថានីយ៍បុរាណវិទ្យានិងសម្បត្តិបេតិកភណ្ឌវប្បធម៌ គ្រប់ប្រភេទនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ការស្រាវជ្រាវរបស់អ្នកនិពន្ធ គឺមិនត្រូវពាក់ពន្ធ័ទៅនឹងសកម្មភាពលួច ឬបំផ្លាញដល់ស្ថានីយ៍បុរាណវិទ្យា និង សារៈសំខាន់នៃសម្បត្តិបេតិកភណ្ឌវប្បធម៌រួមបញ្ចូលទាំងការជួញដូរ ឬលក់ ដោយខុសច្បាប់នូវវត្ថុដែលបានពីកំណាយនិងវត្ថុសិល្បៈដែលមានលក្ខណៈប្រវត្តិសាស្ត្រ។ ការពាក់ព័ន្ធទៅនឹងសកម្មភាពខាងលើនេះ នឹងបង្ហាញឲ្យការខ្វែងគំនិតគ្នា។ ប៉ុន្តែនេះមិនបានរាប់បញ្ចូលនូវការបោះពុម្ពផ្សាយអំពីការស្រាវជ្រាវរកបណ្តាញខុសច្បាប់នោះទេ។

អ្នកនិពន្ធត្រូវបានអនុញ្ញាតអោយប្រើប្រាស់នូវរូបភាពរបស់ពួកគេផ្ទាល់ខ្លួន ឬរូបភាពដែលបានបោះផ្សាយរួចសម្រាប់ប្រើប្រាស់ក្នុងអត្ថបទរបស់ខ្លួន។ អ្នកនិពន្ធត្រូវមានការទទួលខុសត្រូវ ច្បាស់លាស់ក្នុងការសុំសិទ្ធិម្ចាស់កម្មសិទ្ធិចំពោះរូបភាពដែលបានបោះពុម្ពផ្សាយរួចហើយ។ ក្រុមអ្នកត្រួតពិនិត្យរបស់ *ប្រាទូ* អាចជួយក្នុងការទំនាក់ទំនង ទៅម្ចាស់កម្មសិទ្ធិ រួមទាំងក្នុងករណីការប្រើប្រាស់រូបភាពនោះសារឡើងវិញ ត្រូវបង់កម្រៃក៏ដោយ។ ជាការទទួលខុសត្រូវរបស់ *ប្រាទូ* ក្នុងការធានាថារាល់ការសុំការអនុញ្ញាតជំនួសអ្នកនិពន្ធទៅកាន់ម្ចាស់កម្មសិទ្ធនោះ នឹងត្រូវបានគេអនុញ្ញាតឲ្យ។

សូមចុះហត្ថលេខាខាងក្រោម ដើម្បីបញ្ជាក់ពីលោកអ្នកបានយល់អំពីគោលការណ៍ក្នុងការបោះពុម្ពផ្សាយដែលបានរៀបរាប់ខាងលើ និងបញ្ជាក់ថា មិនមានការខ្វែងគំនិតគ្នាណាមួយទេ  រួចសូមផ្ញើលិខិតនេះនិងអត្ថបទរបស់លោកអ្នក តាមរយៈអ៊ីម៉ែល។ ក្នុងករណីអត្ថបទដែលមានអ្នកនិពន្ធរួមគ្នា *ប្រាទូ* នឹងទទួលយកពាក្យស្នើដែលបានចុះហត្ថលេខាពីអ្នកនិពន្ធនីមួយៗ ឬក៏ពាក្យស្នើដែលបានចុះហត្ថលេខាដោយអ្នកនិពន្ធម្នាក់ដែលបានទទួលជាតំណាងនៃអ្នកនិពន្ធទាំងអស់។ សូមបញ្ជាក់ខាងក្រោម ប្រសិនបើមានករណីបែបនេះ។ សូមទាក់ទងមក pratujournal@soas.ac.uk ប្រសិនបើអ្នកមានសំណួរ។

ឈ្មោះ:…………………………………. ហត្ថលេខា:…………………………… កាលបរិច្ឆេទ:…………………………

កំណត់សម្គាល់អ្នកនិពន្ធ (មិនមែនជាការតម្រូវ): ……………………………………………………………..